# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានគណៈមេធាវី**

**មេធាវី លី ច័ន្ទតុលា**

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី សាំង វណ្ណៈ
២-មេធាវី សួស សាមឿន
៣-មេធាវី ទូច ធីរិទ្ធ
៤-មេធាវី មុត ពិសិដ្ឋ
៥-មេធាវី គីម វាសនា
៦-មេធាវី កេង សុម៉ាឡា
៧-មេធាវី លឹម ស៊ីម
៨-មេធាវី នាង បញ្ញា
៩-មេធាវី នៅ ច័ន្ទសុជាតា
១០-មេធាវី លី ចិត្យបូនាមី
១១-មេធាវី យ៉ុន ប៊ុនណា
១២-មេធាវី ប៉ែន សុវណ្ណនី
១៣-មេធាវី កែវ ពេជ្ជនៈ
១៤-មេធាវី អ៊ុង គីរិយា
១៥-មេធាវី យិច សមិទ្ធិ
១៦-មេធាវី សេង ទូចហ៊ុន
១៧-មេធាវី គីម ផលស៊ី
១៨-មេធាវី ជា តារ៉ា
១៩-មេធាវី អ៊ូ ធីតាពៅ
២០-មេធាវី ឆួន សុធា
២១-មេធាវី ខៀវ សំបូរ
២២-មេធាវី គីម សុជាតិ
២៣-មេធាវី ហួន វិទ្យា
២៤-មេធាវី សេង ឈុនលី
២៥-មេធាវី ជា សុភន្ទួន
២៦-មេធាវី កែ ឆដាផស្ស
២៧-មេធាវី កេត ច័ន្ទម៉ានីន
២៨-មេធាវី ខៀវ តុលា
២៩-មេធាវី ហាក់ សុតារិទ្ធ
៣០-មេធាវី សួង សុផល
៣១-មេធាវី គង់ ពិទូ
៣២-មេធាវី លី សុវណ្ណបញ្ញា
៣៣-មេធាវី ស្វាយ សុលីដា

លេខ ៤៨៨ /សសគម/២៤

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យអនុវត្តបទបញ្ជានិងនីតិវិធីនៃការបោះឆ្នោត ជ្រើសតាំងប្រធានគណៈមេធាវី អាណត្តិទី១៥ និងជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី១១

## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ច័ន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៤
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី១០
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤

## ស ម្រេ ច

ដាក់ឱ្យអនុវត្តបទបញ្ជានិងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី អាណត្តិទី១៥(២០២៤-២០២៦) និងការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី១១(២០២៤-២០២៧) ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ ហើយដែលមានខ្លឹមសារទាំងស្រុងដូចតទៅ៖

# ជំពូកទី១
# នីតិវិធីមុនចាប់ផ្តើមការបោះឆ្នោត

## ក- ការត្រួតពិនិត្យឯកសារនិងសម្ភារបោះឆ្នោត

### ១.១. ការត្រួតពិនិត្យឯកសារបោះឆ្នោត

១.១.១. ត្រួតពិនិត្យឡើងវិញ ដើម្បីឱ្យប្រាកដថាសន្លឹកឆ្នោតបានបោះពុម្ពត្រឹមត្រូវ មានបោះត្រាសម្ងាត់គណៈមេធាវី និងមានគ្រប់ចំនួនអាចដំណើរការបោះឆ្នោតបាន។ សន្លឹកឆ្នោតសម្រាប់បោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីមានពីរពណ៌ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតលើកទី១ និងលើកទី២ ករណីលទ្ធផលបោះឆ្នោតលើកទី១ ពុំមានបេក្ខជនណាទទួលបានសំឡេងឆ្នោតគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកគណៈមេធាវីទាំងមូល។ សន្លឹកឆ្នោតសម្រាប់បោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី មានពណ៌ផ្សេងពីសន្លឹកឆ្នោតសម្រាប់បោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី។

១.១.២. ត្រួតពិនិត្យឡើងវិញលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ដើម្បីឱ្យប្រាកដថា បញ្ជីឈ្មោះនោះមានឈ្មោះអ្នកបោះឆ្នោតត្រឹមត្រូវតាមការិយាល័យដែលបានបែងចែកនិងផ្សព្វផ្សាយ។ បញ្ជីឈ្មោះនេះមានចំនួន ៣ គឺ បញ្ជីឈ្មោះសម្រាប់បោះឆ្នោតប្រធានគណៈមេធាវីលើកទី១ បញ្ជីឈ្មោះសម្រាប់បោះឆ្នោតក្រុមប្រឹក្សាគណៈមេធាវី និងបញ្ជីឈ្មោះសម្រាប់បោះឆ្នោតប្រធានគណៈមេធាវីលើកទី២។

១.១.៣. ត្រួតពិនិត្យឡើងវិញលើភាពត្រឹមត្រូវនៃឯកសារពាក់ព័ន្ធផ្សេងៗទៀត ដូចជាកំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោត កំណត់ហេតុបិទការិយាល័យបោះឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោតបឋម និងលិខិតបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោត។

១.១.៤. ក្នុងករណីរកឃើញថាមានភាពមិនប្រក្រតីក្នុងចំណុចណាមួយខាងលើនេះ ត្រូវរាយការណ៍ភ្លាមទៅអគ្គលេខាធិការគណៈមេធាវី និងត្រូវចាត់វិធានការគ្រប់រូបភាពដើម្បីឱ្យមានប្រក្រតីភាពឡើងវិញ។

### ១.២. ការត្រួតពិនិត្យសម្ភារបោះឆ្នោត

១.២.១. ត្រួតពិនិត្យឡើងវិញដើម្បីឱ្យប្រាកដថា ហិបឆ្នោតត្រូវបានដំឡើងត្រឹមត្រូវ និងមានភាពប្រក្រតីអាចដំណើរការបោះឆ្នោតបាន។

១.២.២. ត្រួតពិនិត្យឡើងវិញនូវសោរនិងក្រដាសបិទឃ្លុំហិបឆ្នោត។

១.២.៣. ត្រួតពិនិត្យឡើងវិញថា តើបន្ទប់សម្ងាត់បានរៀបចំត្រឹមត្រូវហើយឬនៅ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសម្ងាត់ សេរី ត្រឹមត្រូវ និងយុត្តិធម៌។

១.២.៤. ត្រួតពិនិត្យនិងសាកល្បងប្រើប៊ិចសម្រាប់គូសលើសន្លឹកឆ្នោត ដើម្បីឱ្យប្រាកដថាប៊ិចនេះអាចប្រើប្រាស់បានដោយរលូន។

១.២.៥. ត្រួតពិនិត្យទ្រនាប់សម្រាប់ទ្រាប់គូសសន្លឹកឆ្នោត។

១.២.៦. ត្រួតពិនិត្យត្រាសម្ងាត់គណៈមេធាវី និងតាំប៉ុងសម្រាប់ត្រៀមបោះលើសន្លឹកឆ្នោតណាដែលមិនទាន់បានបោះត្រា។

១.២.៧. ក្នុងករណីរកឃើញថា មានភាពមិនប្រក្រតីក្នុងចំណុចណាមួយខាងលើនេះ ត្រូវរាយការណ៍ភ្លាមទៅអគ្គលេខាធិការគណៈមេធាវី និងត្រូវចាត់វិធានការគ្រប់រូបភាពដើម្បីឱ្យមានប្រក្រតីភាពឡើងវិញ។

## ខ- បញ្ជីឈ្មោះបេក្ខជនឈរឈ្មោះជាប្រធានគណៈមេធាវីនិងក្រុមប្រឹក្សាគណៈមេធាវី

១.៧. បញ្ជីឈ្មោះបេក្ខជនឈរឈ្មោះជាប្រធានគណៈមេធាវីនិងសមាជិកក្រុមប្រឹក្សាគណៈមេធាវី ត្រូវរៀបតាមលំដាប់កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំឈរឈ្មោះ។ បញ្ជីឈ្មោះបេក្ខជនឈរឈ្មោះជាប្រធានគណៈមេធាវីនិងក្រុមប្រឹក្សាគណៈមេធាវី ត្រូវធ្វើជា២(ពីរ) ផ្សេងគ្នា។

១.៨. បញ្ជីឈ្មោះបេក្ខជនផ្លូវការ ត្រូវមានប្រថាប់ត្រារបស់គណៈមេធាវី។

## គ- បញ្ជីឈ្មោះអ្នកបោះឆ្នោត

១.៩. បញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវធ្វើការបែងចែកជា ៤០ បញ្ជីឈ្មោះផ្សេងៗគ្នាដែលនឹងត្រូវបិទផ្សាយតាមការិយាល័យបោះឆ្នោតចំនួន ៤០។ ដោយឡែកការិយាល័យបោះឆ្នោតទី៤១ បម្រុងទុកសម្រាប់ឱ្យអ្នកបោះឆ្នោតដែលឡើងកំដៅលើសពី ៣៧,៥ អង្សាសេ ធ្វើការបោះឆ្នោត។

១.១០. បញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការ ត្រូវមានប្រថាប់ត្រាគណៈមេធាវីនៅគ្រប់ទំព័រ។

១.១១. ការបែងចែកត្រូវឈរលើអត្តលេខរបស់មេធាវីដែលមានសិទ្ធិបោះឆ្នោត ដោយត្រូវយកចំនួនមេធាវីមានសិទ្ធិបោះឆ្នោតសរុបចែកនឹង៤០ ការិយាល័យបោះឆ្នោត។

១.១២. បញ្ជីឈ្មោះបោះឆ្នោត ត្រូវមានកន្លែងសម្រាប់ចុះហត្ថលេខានិងកន្លែងសម្រាប់ធ្វើកំណត់សម្គាល់ផ្សេងៗ(គំរូបញ្ជីឈ្មោះមានភ្ជាប់ជាឧបសម្ព័ន្ធ)។

## ឃ- ការិយាល័យបោះឆ្នោត

១.១៣. ការិយាល័យបោះឆ្នោត ត្រូវធ្វើការបែងចែកជា៤១(សែសិបមួយ) ការិយាល័យផ្សេងៗគ្នា។

១.១៤. ការិយាល័យបោះឆ្នោតនីមួយៗមានច្រកចូលមួយ និងច្រកចេញមួយដាច់ដោយឡែកពីគ្នា។

១.១៥. ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ១រូប និងមានសមាជិកចំនួន ៤រូប ជាជំនួយការៈ

- សមាជិកទទួលបន្ទុកពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកបោះឆ្នោត ១ រូប
- សមាជិកទទួលបន្ទុកផ្តល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោត ១ រូប
- សមាជិកទទួលបន្ទុកពិនិត្យមើលការដាក់សន្លឹកឆ្នោតចូលក្នុងហិបឆ្នោត ១ រូប
- សមាជិកទទួលបន្ទុកពិនិត្យមើលការតម្រង់ជួរនិងសណ្តាប់ធ្នាប់ ១ រូប

១.១៦. ការិយាល័យបោះឆ្នោតអាចទទួលអ្នកបោះឆ្នោតបានត្រឹមចំនួនដែលមានក្នុងបញ្ជីគ្រប់គ្រងរបស់ខ្លួនប៉ុណ្ណោះ។

១.១៧. ការិយាល័យបោះឆ្នោត ត្រូវបិទនៅម៉ោង ១២:៣០ នាទី ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤ ជាកំហិត។

១.១៨. ការិយាល័យបោះឆ្នោតនីមួយៗត្រូវមានឯកសារនិងសម្ភារដូចខាងក្រោមៈ

- បញ្ជីឈ្មោះអ្នកបោះឆ្នោតចំនួន ២ច្បាប់ សម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវីលើកទី១ និងលើកទី២ និង ១ច្បាប់ សម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាគណៈមេធាវី
- សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីលើកទី១ មានចំនួនស្រប តាមចំនួនអ្នកបោះឆ្នោតក្នុងការិយាល័យរបស់ខ្លួននិងសន្លឹកឆ្នោតបម្រុងចំនួន ២០ច្បាប់
- សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីលើកទី២ មានចំនួនស្រប តាមចំនួនអ្នកបោះឆ្នោតក្នុងការិយាល័យរបស់ខ្លួននិងសន្លឹកឆ្នោតបម្រុងចំនួន ២០ច្បាប់
- សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី មានចំនួនស្រប តាមចំនួនអ្នកបោះឆ្នោតក្នុងការិយាល័យរបស់ខ្លួននិងសន្លឹកឆ្នោតបម្រុងចំនួន ២០ច្បាប់
- ទ្រនាប់សម្រាប់ទ្រាប់គូសសន្លឹកឆ្នោតចំនួន ១០ សម្រាប់ ១០ បន្ទប់សម្ងាត់
- ហិបឆ្នោតចំនួន ២ សម្រាប់ដាក់សន្លឹកឆ្នោតប្រធានគណៈមេធាវី និងសម្រាប់ដាក់សន្លឹកឆ្នោត ក្រុមប្រឹក្សាគណៈមេធាវី
- បន្ទប់សម្ងាត់ចំនួន ១០
- ប៊ិចពណ៌ខៀវចងភ្ជាប់នឹងតុចំនួន ១៥ដើម
- ប៊ិចក្រហមចំនួន ៥ដើម
- បន្ទាត់វែងចំនួន ២ដើម
- កន្ត្រៃកាត់ចំនួន ១
- តុចំនួន ២ (សម្រាប់សមាជិក ៥នាក់)
- តុសម្រាប់ដាក់ទ្រហិបឆ្នោតចំនួន ២
- កៅអីចំនួន ៥
- ស្លាកសម្គាល់សន្លឹកឆ្នោតបានការចំនួន ១
- ស្លាកសម្គាល់សន្លឹកឆ្នោតមិនបានការចំនួន ១
- ស្លាកសម្គាល់សន្លឹកឆ្នោតរាប់ហើយចំនួន ១
- ក្ដារខៀនធំចំនួន ១
- ហ្វឺតពណ៌ខ្មៅនិងខៀវចំនួន ៦
- កៅស៊ូកងសម្រាប់ចងផ្ដោបសន្លឹកឆ្នោតជាបាច់តាមការរៀបចំ
- ថង់សម្រាប់ដាក់សន្លឹកឆ្នោតប្រធានគណៈមេធាវីចំនួន ៦ សម្រាប់ដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ និងសន្លឹកឆ្នោតខូចនៃការបោះឆ្នោតលើកទី១ និងលើកទី២
- ថង់សម្រាប់ដាក់សន្លឹកឆ្នោតក្រុមប្រឹក្សាគណៈមេធាវីចំនួន ៣ (សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ និងសន្លឹកឆ្នោតខូច)
- ថង់ធំសម្រាប់ដាក់ថង់សន្លឹកឆ្នោតប្រធានគណៈមេធាវីសរុបចំនួន ២ សម្រាប់ការបោះឆ្នោត លើកទី១ និងលើកទី២
- ថង់ធំសម្រាប់ដាក់ថង់សន្លឹកឆ្នោតក្រុមប្រឹក្សាគណៈមេធាវីសរុបចំនួន ១

- កំណត់ហេតុប្រគល់-ទទួលសន្លឹកឆ្នោតប្រធានគណៈមេធាវីចំនួន ៥ ច្បាប់ (គំរូមានជាឧបសម្ព័ន្ធទី១-ក)
- កំណត់ហេតុប្រគល់-ទទួលសន្លឹកឆ្នោតប្រធានគណៈមេធាវី (សម្រាប់បោះលើកទី២) ចំនួន ៥ច្បាប់ (គំរូមានជាឧបសម្ព័ន្ធទី១-ខ)
- កំណត់ហេតុប្រគល់-ទទួលសន្លឹកឆ្នោតក្រុមប្រឹក្សាគណៈមេធាវី ចំនួន ៥ច្បាប់ (គំរូមានជាឧបសម្ព័ន្ធទី១-គ)
- កំណត់ហេតុនៃការបោះឆ្នោតនិងបិទការិយាល័យបោះឆ្នោត ចំនួន ៥ច្បាប់ សម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវីលើកទី១និងការបោះឆ្នោតក្រុមប្រឹក្សាគណៈមេធាវី និងចំនួន ៥ច្បាប់ទៀត សម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវីលើកទី២ (គំរូមានជាឧបសម្ព័ន្ធទី២)
- កំណត់ហេតុផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតប្រធានគណៈមេធាវី ចំនួន ៥ច្បាប់សម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវីលើកទី១ និងចំនួន ៥ច្បាប់ទៀត សម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវីលើកទី២ (គំរូមានជាឧបសម្ព័ន្ធទី៣-ក)
- កំណត់ហេតុផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតក្រុមប្រឹក្សាគណៈមេធាវី ចំនួន ៥ច្បាប់ (គំរូមានជាឧបសម្ព័ន្ធទី៣-ខ)
- កំណត់ហេតុបូកសរុបលទ្ធផលបឋមសម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវី ចំនួន ៥ច្បាប់ សម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវីលើកទី១ និងចំនួន ៥ច្បាប់ទៀត សម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវីលើកទី២(គំរូមានជាឧបសម្ព័ន្ធទី៤-ក)
- កំណត់ហេតុបូកសរុបលទ្ធផលបឋមសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាគណៈមេធាវី ចំនួន ៥ច្បាប់ (គំរូមានជាឧបសម្ព័ន្ធទី៤-ខ)
- របាយការណ៍បូកសរុបលទ្ធផលផ្លូវការសម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវី ចំនួន ៥ច្បាប់ សម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវីលើកទី១ និងចំនួន ៥ ច្បាប់ទៀត សម្រាប់ការបោះឆ្នោតប្រធានគណៈមេធាវីលើកទី២ (គំរូមានជាឧបសម្ព័ន្ធទី៥-ក)
- របាយការណ៍បូកសរុបលទ្ធផលផ្លូវការសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាគណៈមេធាវីចំនួន ៥ ច្បាប់ (គំរូមានជាឧបសម្ព័ន្ធទី៥-ខ)

១.១៩. ប្រធាននិងសមាជិកការិយាល័យនីមួយៗ ត្រូវអនុវត្តការងាររបស់ខ្លួន ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងត្រូវរាយការណ៍អំពីភាពមិនប្រក្រតីនានាដែលកើតមានឡើងទៅប្រធានគណៈកម្មការបោះឆ្នោត ដើម្បីដាក់ចេញនូវវិធានទប់ស្កាត់។

## ង- អ្នកសង្កេតការណ៍បោះឆ្នោត

១.២០. បេក្ខជនឈរឈ្មោះប្រធានគណៈមេធាវី អាចស្នើសុំការទទួលស្គាល់អ្នកសង្កេតការណ៍ជាមេធាវីពេញសិទ្ធិនិងមេធាវីកម្មសិក្សា មិនលើសពីចំនួន ៤១រូប សម្រាប់សង្កេតការណ៍បោះឆ្នោត។ បេក្ខជនឈរឈ្មោះក្រុមប្រឹក្សាគណៈមេធាវី អាចស្នើសុំការទទួលស្គាល់អ្នកសង្កេតការណ៍ជា

មេធាវីពេញសិទ្ធិនិងមេធាវីកម្មសិក្សា មិនលើសពីចំនួន ១រូប សម្រាប់សង្កេតការណ៍បោះឆ្នោត។

១.២១. អ្នកសង្កេតការណ៍មានសិទ្ធិត្រួតពិនិត្យមើលរាល់សកម្មភាពទាំងអស់ដែលកើតមានក្នុងការិយាល័យបោះឆ្នោត លើកលែងតែសកម្មភាពណាដែលប៉ះពាល់ដល់ការសម្ងាត់នៃការបោះឆ្នោត។

១.២២. អ្នកសង្កេតការណ៍ពុំមានសិទ្ធិបង្គាប់បញ្ជាគណៈកម្មការបោះឆ្នោតឱ្យធ្វើតាមខ្លួននោះទេ ប៉ុន្តែអាចកត់ត្រាទុកនូវកំហុសនានា បើរកឃើញមានកំហុសនីតិវិធីកើតឡើង។

## ជំពូកទី ២
## នីតិវិធីក្នុងដំណើរការបោះឆ្នោត

### ក- ការណែនាំអំពីរបៀបនិងនីតិវិធីនៃការបោះឆ្នោតប្រធានគណៈមេធាវីនិងក្រុមប្រឹក្សាគណៈមេធាវី

២.១. ការបោះឆ្នោតត្រូវចាប់ផ្តើមនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤ ទៅតាមពេលវេលាដែលបានកំណត់ និងត្រូវបិទនៅម៉ោង ១២:៣០ នាទី នាថ្ងៃដដែលជាកំហិត។

២.២. ប្រធានគណៈកម្មការបោះឆ្នោតឬតំណាង ត្រូវឡើងបង្ហាញជូនអង្គបោះឆ្នោតទាំងអស់ដោយសង្ខេបអំពីរបៀបនិងនីតិវិធីនៃការបោះឆ្នោត នៅក្នុងអង្គមហាសន្និបាតគណៈមេធាវី។

២.៣. ការបង្ហាញជូននេះ ត្រូវផ្អែកលើខ្លឹមសារដូចមានក្នុងជំពូកទី២ ចំណុច ខ ខាងក្រោមនេះ។

### ខ- អ្នកបោះឆ្នោត

២.៤. អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅការិយាល័យណាមួយ ត្រូវទៅបោះឆ្នោតនៅការិយាល័យនោះ។

២.៥. អ្នកបោះឆ្នោតត្រូវអញ្ជើញទៅបោះឆ្នោតតាមការិយាល័យ ដែលឈ្មោះខ្លួនស្ថិតនៅតាមលំដាប់លេខរៀងនៃអត្តលេខឬការមកដល់ការិយាល័យបោះឆ្នោត។ ក្នុងករណីអ្នកបោះឆ្នោតបានទទួលការប្រគល់សិទ្ធិបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវអញ្ជើញទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលមានបញ្ជីឈ្មោះអ្នកប្រគល់សិទ្ធិបោះឆ្នោត បន្ទាប់ពីបោះឆ្នោតសម្រាប់ខ្លួនឯងរួចហើយ។

២.៦. អ្នកបោះឆ្នោតត្រូវបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណ ដល់សមាជិកការិយាល័យបោះឆ្នោតដើម្បីបញ្ជាក់អំពីលក្ខណៈសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត និងលិខិតប្រគល់-ទទួលសិទ្ធិបោះឆ្នោត ក្នុងករណីបោះឆ្នោតជំនួសអ្នកប្រគល់សិទ្ធិបោះឆ្នោត។

២.៧. ឯកសារបញ្ជាក់អត្តសញ្ញាណដែលត្រូវបង្ហាញនិងទទួលយកថាបានការ គឺប័ណ្ណសម្គាល់ខ្លួនមេធាវីដែលចេញដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយស្ថិតក្នុងសុពលភាព។

២.៨. អ្នកដែលបាត់ប័ណ្ណសម្គាល់ខ្លួនមេធាវី ត្រូវសុំលិខិតបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោតពីប្រធានគណៈមេធាវី។ លិខិតបញ្ជាក់នេះអាចទៅសុំពីអគ្គលេខាធិការគណៈមេធាវី (ក្រុមបញ្ជាក់ឯកសារអត្តសញ្ញាណ)។ ការសុំបញ្ជាក់អត្តសញ្ញាណនេះ ត្រូវមានហត្ថលេខាអ្នកស្នើសុំ (គំរូពាក្យសុំនិងលិខិតបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោតមានជាឧបសម្ព័ន្ធ)។

២.៩. ដើម្បីរក្សាសណ្តាប់ធ្នាប់និងរបៀបរៀបរយ អ្នកបោះឆ្នោតត្រូវស្តាប់តាមការណែនាំរបស់សមាជិកការិយាល័យបោះឆ្នោតទទួលបន្ទុកពិនិត្យមើលការតម្រង់ជួរនិងសណ្តាប់ធ្នាប់។

២.១០.សម្រាប់អ្នកទទួលសិទ្ធិពីសហភាតា ត្រូវប្រគល់លិខិតប្រគល់-ទទួលសិទ្ធិបោះឆ្នោតដែលត្រឹមត្រូវតាមការកំណត់របស់ប្រធានគណៈមេធាវី ជូនទៅគណៈមេធាវីឱ្យបានត្រឹមថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៤ ឬប្រគល់ជូនក្រុមការងារទទួលនិងពិនិត្យលិខិតប្រគល់-ទទួលសិទ្ធិបោះឆ្នោតនៅថ្ងៃមហាសន្និបាត ឱ្យបានមុនពេលបិទការិយាល័យបោះឆ្នោត។ គណៈកម្មការបោះឆ្នោតត្រូវកត់សម្គាល់ឈ្មោះអ្នកប្រគល់សិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត តាមគំរូណែនាំនៅក្នុងបញ្ជីបោះឆ្នោត។

២.១១.មេធាវីដែលមានសិទ្ធិបោះឆ្នោត ហើយដែលមិនត្រូវបានដកហូតសិទ្ធិបោះឆ្នោត មានសិទ្ធិប្រគល់សិទ្ធិបោះឆ្នោតប្រធានគណៈមេធាវីនិង/ឬក្រុមប្រឹក្សាគណៈមេធាវី ឱ្យទៅសហភាតាដែលមានសិទ្ធិបោះឆ្នោតបាន (គំរូលិខិតប្រគល់-ទទួលសិទ្ធិបោះឆ្នោតមានជាឧបសម្ព័ន្ធ)។ មេធាវីមានសិទ្ធិបោះឆ្នោត ១រូប មានសិទ្ធិទទួលបានការប្រគល់សិទ្ធិបោះឆ្នោតប្រធានគណៈមេធាវីនិង/ឬក្រុមប្រឹក្សាគណៈមេធាវី ពីសហភាតាតែម្នាក់ប៉ុណ្ណោះ។ មេធាវីដែលបានប្រគល់សិទ្ធិឱ្យសហភាតាបោះឆ្នោតប្រធានគណៈមេធាវីនិង/ឬក្រុមប្រឹក្សាគណៈមេធាវីជំនួសខ្លួនរួចហើយអាចដកយកលិខិតប្រគល់សិទ្ធិបោះឆ្នោតប្រធានគណៈមេធាវីនិង/ឬក្រុមប្រឹក្សាគណៈមេធាវីនេះត្រឡប់មកវិញបាន លុះត្រាតែអ្នកទទួលសិទ្ធិមិនទាន់បានបោះឆ្នោតសម្រាប់ការផ្ទេរសិទ្ធិបោះឆ្នោតប្រធានគណៈមេធាវីនិង/ឬក្រុមប្រឹក្សាគណៈមេធាវីនោះនៅឡើយ។ បើមានវិវាទទាក់ទងនឹងមេធាវីដែលមានសិទ្ធិបោះឆ្នោត បានប្រគល់សិទ្ធិបោះឆ្នោតប្រធានគណៈមេធាវីនិង/ឬក្រុមប្រឹក្សាគណៈមេធាវីឱ្យទៅសហភាតាលើសពីម្នាក់ លិខិតផ្ទេរសិទ្ធិទាំងអស់ត្រូវទុកជាមោឃៈ លើកលែងតែគណៈកម្មការការិយាល័យបោះឆ្នោតបានដឹងហេតុការណ៍នេះ ក្រោយពេលដែលសហភាតាណាមួយបានបោះឆ្នោតជំនួសអ្នកប្រគល់សិទ្ធិនោះរួចហើយ។ ក្នុងករណីនេះ លិខិតប្រគល់សិទ្ធិផ្សេងទៀតដែលមិនទាន់បានបោះឆ្នោត ត្រូវទុកជាមោឃៈ។

២.១២.មេធាវីដែលត្រូវបានទទួលរងនូវទណ្ឌកម្មវិន័យដកសិទ្ធិបោះឆ្នោតពុំមានសិទ្ធិបោះឆ្នោតឡើយ។

២.១៣.ប្រធាននិងសមាជិកគណៈកម្មការបោះឆ្នោតទាំងអស់ក្នុងការិយាល័យបោះឆ្នោត ត្រូវបោះឆ្នោតមុនអ្នកបោះឆ្នោតដទៃទៀត ដើម្បីបន្តបំពេញភារកិច្ចរបស់ខ្លួន។ បន្ទាប់មក ប្រធានគណៈមេធាវី អតីតប្រធានគណៈមេធាវី សមាជិកក្រុមប្រឹក្សាគណៈមេធាវី និងអគ្គលេខាធិការ ត្រូវបោះឆ្នោតបន្ទាប់ មុននឹងអនុញ្ញាតឱ្យសមាជិក-សមាជិកាគណៈមេធាវីបោះឆ្នោត។

២.១៤.អ្នកបោះឆ្នោតអាចចូលទៅបោះឆ្នោតម្តងបានដប់នាក់ក្នុងបន្ទប់សម្ងាត់ផ្សេងៗគ្នា។

២.១៥.ហាមអ្នកបោះឆ្នោតប្រើប្រាស់ទូរស័ព្ទដៃនិងម៉ាស៊ីនថតរូបនៅពេលបោះឆ្នោត (បម្រាមមានជាឧបសម្ព័ន្ធ)។

## គ- ការគ្រប់គ្រងសន្លឹកឆ្នោតនិងហិបឆ្នោត

២.១៦.មុនពេលបោះឆ្នោត ប្រធានគណៈកម្មការបោះឆ្នោតត្រូវធ្វើកំណត់ហេតុប្រគល់-ទទួលសន្លឹកឆ្នោតឱ្យទៅប្រធានការិយាល័យបោះឆ្នោតតាមគំរូដែលបានផ្តល់ជូន។ កំណត់ហេតុត្រូវមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត

ទាំងអស់ ព្រមទាំងអ្នកសង្កេតការណ៍(ប្រសិនបើមាន)។ ការមិនព្រមចុះហត្ថលេខារបស់អ្នកសង្កេតការណ៍ មិនអាចធ្វើឱ្យកំណត់ហេតុនេះលែងមានសុពលភាពនោះទេ។

ឃ- ការផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកបោះឆ្នោត

២.១៧. សមាជិកទទួលបន្ទុកពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកបោះឆ្នោតនីមួយៗត្រូវ៖

- ផ្ទៀងផ្ទាត់ឯកសារបញ្ជាក់អត្តសញ្ញាណទៅនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានរៀបតាមអត្តលេខ
- ផ្ទៀងផ្ទាត់មើលរូបថតដែលមានលើប័ណ្ណសម្គាល់ខ្លួនមេធាវី ឬលិខិតបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោត ជាមួយនឹងមុខមាត់ផ្ទាល់របស់អ្នកបោះឆ្នោត
- ជម្រាបអ្នកបោះឆ្នោតឱ្យចុះហត្ថលេខា នៅក្នុងប្រអប់បន្ទាត់ឈ្មោះរបស់អ្នកបោះឆ្នោតក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត
- ក្នុងករណីអ្នកបោះឆ្នោតទទួលសិទ្ធិពីសហភាគាឱ្យបោះឆ្នោតប្រធានគណៈមេធាវីនិង/ឬក្រុមប្រឹក្សាគណៈមេធាវីជំនួស ត្រូវឱ្យចុះហត្ថលេខានៅក្នុងប្រអប់បន្ទាត់ឈ្មោះរបស់សហភាគាដែលប្រគល់សិទ្ធិក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងកត់ឈ្មោះមេធាវីដែលទទួលសិទ្ធិបោះឆ្នោតនោះ
- ជម្រាបអ្នកបោះឆ្នោតឱ្យទៅទទួលយកសន្លឹកឆ្នោត ពីសមាជិកទទួលបន្ទុកផ្តល់ សន្លឹកឆ្នោត។

ង- ការប្រគល់សន្លឹកឆ្នោត

២.១៨. ករណីអ្នកបោះឆ្នោតមិនបានប្រគល់សិទ្ធិជូនសហភាគាណាមួយ អ្នកបោះឆ្នោតនោះត្រូវទទួលបានសន្លឹកឆ្នោតពីរសន្លឹកពីសមាជិកទទួលបន្ទុកផ្តល់សន្លឹកឆ្នោត ដែលសន្លឹកឆ្នោតមួយជាសន្លឹកឆ្នោតសម្រាប់ប្រធានគណៈមេធាវី និងសន្លឹកឆ្នោតមួយទៀតជាសន្លឹកឆ្នោតក្រុមប្រឹក្សាគណៈមេធាវី រួចធ្វើការបោះឆ្នោតសម្រាប់ខ្លួនឯង។

២.១៩. ករណីអ្នកបោះឆ្នោតបានទទួលការប្រគល់សិទ្ធិពីសហភាគាណាមួយ ដើម្បីបោះឆ្នោតជំនួស អ្នកបោះឆ្នោតនោះត្រូវទៅកាន់ការិយាល័យរបស់ឈ្មោះអ្នកប្រគល់សិទ្ធិ ដើម្បីទទួលបានសន្លឹកឆ្នោតចំនួនមួយ ឬពីរសន្លឹកទៅតាមការប្រគល់សិទ្ធិ ពីសមាជិកទទួលបន្ទុកផ្តល់សន្លឹកឆ្នោត រួចធ្វើការបោះឆ្នោតជំនួស។

២.២០. ក្នុងករណីសន្លឹកឆ្នោតរហែក ឬខូច អ្នកបោះឆ្នោតត្រូវយកសន្លឹកឆ្នោតនោះមកដូរសន្លឹកឆ្នោតថ្មីបាន។

២.២១. សមាជិកទទួលបន្ទុកផ្តល់សន្លឹកឆ្នោតនីមួយៗត្រូវប្រគល់សន្លឹកឆ្នោត ដែលបានត្រៀមរួចជាស្រេចជូនទៅអ្នកបោះឆ្នោត ដោយត្រូវឱ្យប្រាកដថា សន្លឹកឆ្នោតដែលខ្លួនប្រគល់ជូនអ្នកបោះឆ្នោតនោះមានត្រាសម្គាល់និងត្រាសម្ងាត់ត្រឹមត្រូវ។

២.២២. សមាជិកទទួលបន្ទុកផ្តល់សន្លឹកឆ្នោតត្រូវបត់សន្លឹកឆ្នោតជា ៣ផ្នត់ តាមការណែនាំ រួចជម្រាបទៅអ្នកបោះឆ្នោតឱ្យចូលបន្ទប់សម្ងាត់ ដើម្បីបោះឆ្នោត។

២.២៣. ក្រោយពីគូសគាំទ្ររួច អ្នកបោះឆ្នោតត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដែលបានបត់រួចស៊កបញ្ចូលសន្លឹកឆ្នោតប្រធានគណៈមេធាវីទៅក្នុងហិបឆ្នោតប្រធាន និងស៊កបញ្ចូលសន្លឹកឆ្នោតក្រុមប្រឹក្សាគណៈមេធាវីទៅក្នុងហិបឆ្នោតក្រុមប្រឹក្សារួចចាកចេញពីការិយាល័យបោះឆ្នោតតាមច្រកចេញមួយផ្សេងទៀត តាមការណែនាំរបស់សមាជិកទទួលបន្ទុកពិនិត្យមើលការដាក់សន្លឹកឆ្នោតចូលក្នុងហិបឆ្នោត។ សន្លឹកឆ្នោតដែលមិនបានដាក់ចូលក្នុងហិបឆ្នោតត្រូវចាត់ទុកជាសន្លឹកឆ្នោតមិនបានការ និងពុំត្រូវយកមករាប់ឡើយ។

## ច- ការធ្វើកំណត់ហេតុនៃការបោះឆ្នោត

២.២៤. បន្ទាប់ពីអ្នកបោះឆ្នោតបានបោះឆ្នោតគ្រប់គ្នាហើយ ប្រធានការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ហេតុនៃការបោះឆ្នោត តាមគំរូដែលបានផ្តល់ជូន។

២.២៥. កំណត់ហេតុនៃការបោះឆ្នោតត្រូវមានព័ត៌មានសំខាន់ៗមួយចំនួនដូចជា លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ចំនួនអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើអស់ ចំនួនសន្លឹកឆ្នោតខូច និងកំណត់សម្គាល់ពាក់ព័ន្ធនឹងភាពមិនប្រក្រតីផ្សេងៗ។

២.២៦. កំណត់ហេតុត្រូវមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោតទាំងអស់ ព្រមទាំងអ្នកសង្កេតការណ៍(ប្រសិនបើមាន)។ ការមិនព្រមចុះហត្ថលេខារបស់អ្នកសង្កេតការណ៍ មិនអាចធ្វើឱ្យកំណត់ហេតុនេះលែងមានសុពលភាពនោះទេ។

២.២៧. កំណត់ហេតុនេះត្រូវរៀបចំដាច់ដោយឡែក តាមការិយាល័យនីមួយៗ។

## ឆ- ការបិទការិយាល័យបោះឆ្នោតនិងការធ្វើកំណត់ហេតុបិទការិយាល័យបោះឆ្នោត

២.២៨. ការិយាល័យបោះឆ្នោតត្រូវបិទនៅម៉ោង ១២:៣០ នាទី នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤ ហើយអ្នកបោះឆ្នោតដែលនៅក្នុងបរិវេណការិយាល័យបោះឆ្នោត អាចបន្តបោះឆ្នោតរហូតគ្រប់គ្នា។ ក្នុងករណីឈ្មោះក្នុងបញ្ជីបោះឆ្នោតរបស់ការិយាល័យបោះឆ្នោតណាមួយត្រូវបានបោះឆ្នោតគ្រប់ចំនួន ការិយាល័យនោះត្រូវបានបិទមុនម៉ោងកំណត់បាន។

២.២៩. ប្រធានការិយាល័យបោះឆ្នោតត្រូវចាត់ចែងធ្វើកំណត់ហេតុបិទការិយាល័យបោះឆ្នោតតាមគំរូដែលបានផ្តល់ជូន។

២.៣០. កំណត់ហេតុត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីពេលវេលានៃការបិទការិយាល័យ ហើយត្រូវមានចុះហត្ថលេខារបស់គណៈកម្មការការិយាល័យបោះឆ្នោតទាំងអស់ និងអ្នកសង្កេតការណ៍(ប្រសិនបើមាន)។ ការមិនព្រមចុះហត្ថលេខារបស់អ្នកសង្កេតការណ៍ មិនអាចធ្វើឱ្យកំណត់ហេតុនេះ លែងមានសុពលភាពនោះទេ។

# ជំពូកទី ៣
# នីតិវិធីក្នុងដំណើរការផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោត
# សម្រាប់ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី

ក- ការផ្ទៀងផ្ទាត់ និងការកំណត់សន្លឹកឆ្នោតបានការឬមិនបានការ

៣.១. ការរាប់សន្លឹកឆ្នោតត្រូវចាប់ផ្តើមបន្ទាប់ពីបិទការិយាល័យបោះឆ្នោត នៅចំពោះមុខអ្នកដែលមានវត្តមានជាក់ស្តែងនៅក្នុងមហាសន្និបាត។

៣.២. ការផ្ទៀងផ្ទាត់សន្លឹកឆ្នោតដែលបានបោះរួច ជាមួយនឹងឈ្មោះអ្នកដែលបានមកបោះឆ្នោតជាក់ស្តែង រួមទាំងអ្នកប្រគល់សិទ្ធិបោះឆ្នោត ត្រូវធ្វើឡើងតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ។

៣.៣. ការិយាល័យបោះឆ្នោតនឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត ហើយគណៈកម្មការការិយាល័យបោះឆ្នោតទាំងអស់នឹងក្លាយជាគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត នៅពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត។

៣.៤. ប្រធានការិយាល័យបោះឆ្នោត នឹងក្លាយជាប្រធានការិយាល័យរាប់សន្លឹកឆ្នោត ដែលមានតួនាទីកាត់សោឃ្លុំហិបឆ្នោត និងយកសន្លឹកឆ្នោតម្តងមួយៗចេញពីក្នុងហិបឆ្នោត ដើម្បីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ជាមួយនឹងសមាជិកទទួលបន្ទុកផ្ទៀងផ្ទាត់សន្លឹកឆ្នោត (១ រូប) និងជាអ្នកប្រកាសសំឡេងឆ្នោត។

៣.៥. សមាជិកទទួលបន្ទុកពិនិត្យនិងផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកបោះឆ្នោតនឹងក្លាយជាសមាជិកទទួលបន្ទុកផ្ទៀងផ្ទាត់សន្លឹកឆ្នោតដែលបានបោះរួច ជាមួយនឹងឈ្មោះអ្នកដែលបានមកបោះឆ្នោត និងកំណត់ថា ជាសន្លឹកឆ្នោតបានការឬមិនបានការ និងជាអ្នកកត់ត្រាសំឡេងឆ្នោតក្នុងកុំព្យូទ័រ។

៣.៦. សមាជិកទទួលបន្ទុកផ្តល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតនឹងក្លាយជាសមាជិកទទួលកត់ត្រា និងធ្វើកំណត់ហេតុនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនេះ និងជាអ្នកគូសសំឡេងឆ្នោតលើក្រដាស។

៣.៧. សមាជិកទទួលបន្ទុកពិនិត្យមើលការតម្រង់ជួរនិងសណ្តាប់ធ្នាប់ និងសមាជិកទទួលបន្ទុកមើលការដាក់សន្លឹកឆ្នោតក្នុងហិបឆ្នោត នឹងក្លាយជាសមាជិកទទួលរៀបចំនិងរៀបរយសន្លឹកឆ្នោតតាមពំនូកនៃសន្លឹកឆ្នោតបានការនិងសន្លឹកឆ្នោតមិនបានការ និងជាអ្នកគូសសំឡេងឆ្នោតនៅលើក្តារខៀន។

៣.៨. ប្រធានគណៈកម្មការបោះឆ្នោតឬតំណាង ត្រូវឡើងបង្ហាញជូនអង្គបោះឆ្នោតទាំងអស់ដោយសង្ខេបអំពីនីតិវិធីនៃការរាប់សន្លឹកឆ្នោត។

៣.៩. ក្នុងការផ្ទៀងផ្ទាត់ ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវកាត់សោឃ្លុំហិបឆ្នោតប្រធានគណៈមេធាវី រួចបើកយកសន្លឹកឆ្នោតម្តងមួយៗចេញពីហិបឆ្នោត ដើម្បីរាប់ចំនួនសន្លឹកឆ្នោតដោយផ្ទៀងផ្ទាត់ជាមួយនឹងចំនួនឈ្មោះអ្នកបោះឆ្នោត។

៣.១០. សមាជិកទទួលបន្ទុកផ្ទៀងផ្ទាត់សន្លឹកឆ្នោតត្រូវជួយប្រធានក្នុងការផ្ទៀងផ្ទាត់តួលេខនេះ។

៣.១១. ក្រោយពីពិនិត្យរួច សមាជិកទទួលបន្ទុកកត់ត្រាកំណត់ហេតុនៃការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត

ដែលបានបោះរួចជាមួយនឹងឈ្មោះអ្នកបោះឆ្នោតត្រូវធ្វើកំណត់ហេតុនៃការពិនិត្យសន្លឹកឆ្នោត។ កំណត់ហេតុនេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីចំនួនសន្លឹកឆ្នោតជាក់ស្តែងដែលបានប្រើនិងចំនួនអ្នកបោះឆ្នោតជាក់ស្តែង ហើយត្រូវមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការបោះឆ្នោតគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ព្រមទាំងអ្នកសង្កេតការណ៍ (ប្រសិនបើមាន)។ ការមិនព្រមចុះហត្ថលេខារបស់អ្នកសង្កេតការណ៍ មិនអាចធ្វើឱ្យកំណត់ហេតុបូកសរុបលទ្ធផលបឋមនេះ លែងមានសុពលភាពនោះទេ។

៣.១២. បន្ទាប់មក ប្រធានការិយាល័យចាប់ផ្តើមលើកយកសន្លឹកឆ្នោតម្តងមួយៗមកពិនិត្យ ថាតើសន្លឹកឆ្នោតបានការឬមិនបានការដូចមានកំណត់ក្នុងចំណុច ៣.១៩ និង ៣.២០ ខាងក្រោម ដោយមានសមាជិកទទួលបន្ទុកផ្ទៀងផ្ទាត់សន្លឹកឆ្នោតជាជំនួយការក្នុងការពិនិត្យ អមដោយអ្នកសង្កេតការណ៍(ប្រសិនបើមាន)។

៣.១៣. ក្នុងករណីសន្លឹកឆ្នោតពិបាកក្នុងការកំណត់ថាជាសន្លឹកឆ្នោតបានការឬមិនបានការ ឬពិបាកកំណត់ពីគំនូសគាំទ្រ ប្រធានការិយាល័យត្រូវទុកសន្លឹកឆ្នោតនោះដោយឡែក ដើម្បីរង់ចាំពិនិត្យឡើងវិញនៅពេលក្រោយ។

៣.១៤. ការកំណត់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ និងការពិនិត្យលើគំនូសគាំទ្រ ត្រូវធ្វើដោយយកចិត្តទុកដាក់បំផុត ដោយត្រូវត្រួតពិនិត្យម្តងមួយៗរហូតដល់អស់សន្លឹកឆ្នោត។

៣.១៥. ក្រោយពីពិនិត្យសន្លឹកឆ្នោតបានការរួចរាល់ហើយ ប្រធានការិយាល័យរាប់សន្លឹកឆ្នោត ត្រូវយកសន្លឹកឆ្នោតដែលមានបញ្ហាមកពិនិត្យឡើងវិញ ដើម្បីកំណត់ថាជាសន្លឹកឆ្នោតបានការឬមិនបានការ រួចធ្វើការសម្រេចជាចុងក្រោយ។

៣.១៦. សមាជិកទទួលបន្ទុកកត់ត្រានិងធ្វើកំណត់ហេតុនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោត ត្រូវអង្គុយនៅតុ ហើយត្រៀមគូសសំឡេងឆ្នោតតាមការហៅរបស់ប្រធាននៅលើក្រដាស ដើម្បីផ្ទៀងផ្ទាត់ជាមួយអ្នកគូសនៅលើក្តារខៀន និងត្រៀមសម្រាប់ធ្វើកំណត់ហេតុនៃការបូកសរុបលទ្ធផល។

៣.១៧. ក្នុងពេលកំពុងផ្ទៀងផ្ទាត់សន្លឹកឆ្នោត សមាជិកដែលត្រូវគូសសំឡេងឆ្នោតនៅលើក្តារខៀន ត្រូវចាត់ចែងរៀបចំឱ្យហើយនូវក្តារខៀនចំនួន ១ ដោយត្រូវសរសេរឱ្យរួចរាល់ផងដែរនូវលេខរៀងរបស់បេក្ខជន តាមលំដាប់ដូចមានក្នុងសន្លឹកឆ្នោត។

៣.១៨. សមាជិកទទួលរៀបចំនិងរៀបរយសន្លឹកឆ្នោត ត្រូវរៀបចំសន្លឹកឆ្នោតឱ្យមានសណ្តាប់ធ្នាប់ជាពំនូកសម្រាប់ត្រៀមឈានដល់ដំណាក់កាលរាប់សន្លឹកឆ្នោត និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត។

## ខ- លក្ខណៈសម្គាល់នៃសន្លឹកឆ្នោតបានការឬមិនបានការ

៣.១៩. សន្លឹកឆ្នោតបានការ គឺជាសន្លឹកឆ្នោតរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានត្រាសម្គាល់និងត្រាសម្ងាត់ត្រឹមត្រូវ(ត្រាសើមគណៈមេធាវីនិងត្រាស្ងួតគណៈមេធាវី) និងជាសន្លឹកឆ្នោតដែលមានគំនូសគាំទ្រត្រឹមត្រូវ ព្រមទាំងមានគំនូសគាំទ្របេក្ខជនមិនលើសពីចំនួន ១ រូប។

៣.២០. សន្លឹកឆ្នោតមិនបានការ គឺជាសន្លឹកឆ្នោតដែលគ្មានត្រាសម្គាល់និងត្រាសម្ងាត់ត្រឹមត្រូវ (ត្រាសើមគណៈមេធាវីនិងត្រាស្ងួតគណៈមេធាវី) ឬមានគំនូសសញ្ញាគាំទ្រមិនច្បាស់លាស់ មិនមានគំនូសអ្វីទាំងអស់ មានគំនូសក្រៅប្រអប់ មានគំនូសគាំទ្របេក្ខជនលើសពីចំនួន ១ រូប សន្លឹកឆ្នោតដាច់ឬរហែក សន្លឹកឆ្នោតមានប្រឡាក់ប្រតាកដែលមិនអាចកំណត់ការគាំទ្របាន ឬសន្លឹកឆ្នោតដែលមានគូសទឹកប៊ិចក្រៅពីពណ៌ខៀវឬខ្មៅ។

គ- ការរាប់សន្លឹកឆ្នោត និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត

៣.២១. ការរាប់សន្លឹកឆ្នោតនឹងត្រូវចាប់ផ្តើមនៅពេលដែលប្រធានការិយាល័យនីមួយៗ ប្រកាសបិទការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនិងប្រកាសចាប់ផ្តើមរាប់សន្លឹកឆ្នោត។

៣.២២. បន្ទាប់មកប្រធានត្រូវយកសន្លឹកឆ្នោតបានការមកប្រកាសការគាំទ្របេក្ខជនណាមួយឱ្យឮៗ ដើម្បីឱ្យអ្នកគូសសំឡេងឆ្នោតលើក្តារខៀន លើក្រដាស និងកត់ត្រាក្នុងកុំព្យូទ័រ គូសតាម។ ការគូសសំឡេងគាំទ្រលើក្រដាសនិងលើក្តារខៀន ត្រូវគូសម្តងមួយ មានរាងជាប្រអប់បួនជ្រុង និងបន្ទាត់បញ្ឆិតចំកណ្តាលស្មើនឹង ៥។

៣.២៣. សមាជិកកត់ត្រាសន្លឹកឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ ត្រូវបញ្ចូលទិន្នន័យសំឡេងឆ្នោតតាមការរាប់របស់ប្រធានការិយាល័យបោះឆ្នោតនីមួយៗ ធ្វើយ៉ាងណាឱ្យលទ្ធផលនេះស្របនឹងលទ្ធផលដែលគូសដោយដៃនិងលើក្តារខៀន។

៣.២៤. សន្លឹកឆ្នោតបានការដែលបានរាប់រួច ត្រូវទុកក្នុងពំនូកដោយឡែកមួយទៀត ដែលមានស្លាកសម្គាល់ថា "សន្លឹកឆ្នោតរាប់រួច"។

៣.២៥. បន្ទាប់ពីរាប់សន្លឹកឆ្នោតរួច ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវចាត់ចែងឱ្យសមាជិកណាម្នាក់ចងសន្លឹកឆ្នោតបានការមួយពំនូក និងសន្លឹកឆ្នោតមិនបានការមួយពំនូក រួចដាក់ប្រកចូលក្នុងថង់ប្លាស្ទិកធំរួមមួយ។ បន្ទាប់មកចាត់ចែងឱ្យមានការបូកសរុបលទ្ធផលបឋម។

ឃ- ការបូកសរុបលទ្ធផលបឋមនៃការបោះឆ្នោត

៣.២៦. សមាជិកទទួលបន្ទុកកត់ត្រានិងធ្វើកំណត់ហេតុនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោត នឹងក្លាយជាសមាជិកទទួលបន្ទុកបូកសរុបលទ្ធផលបោះឆ្នោត។

៣.២៧. បន្ទាប់ពីរាប់សន្លឹកឆ្នោតរួច សមាជិកគូសសម្លេងឆ្នោតលើក្តារខៀនត្រូវបូកសរុបលទ្ធផលបោះឆ្នោតនៅលើក្តារខៀន ហើយសមាជិកទទួលបន្ទុកបូកសរុបលទ្ធផលបោះឆ្នោតត្រូវធ្វើការបូកសរុបលទ្ធផល នៅលើកំណត់ហេតុបូកសរុបលទ្ធផលបឋមសម្រាប់ការិយាល័យនីមួយៗ (គំរូមានជាឧបសម្ព័ន្ធ)។

៣.២៨. បន្ទាប់មក ត្រូវធ្វើការផ្ទៀងផ្ទាត់គ្នារវាងការបូកសរុបលទ្ធផលបឋម ដោយសមាជិកគូសសំឡេងឆ្នោតលើក្តារខៀន និងសមាជិកទទួលបន្ទុកបូកសរុបលទ្ធផលបោះឆ្នោតនៅលើកំណត់ហេតុ។

៣.២៩. ប្រសិនបើតួលេខមិនស៊ីគ្នា ប្រធានការិយាល័យត្រូវស្វែងរកចំណុចមិនប្រក្រតីទាំងនោះ ហើយក្នុងករណីធ្ងន់ធ្ងរមិនអាចរកឃើញចំណុចមិនប្រក្រតី ចាំបាច់ត្រូវធ្វើការរាប់សន្លឹកឆ្នោត

ឡើងវិញ។

៣.៣០. កំណត់ហេតុបូកសរុបលទ្ធផលបឋម ត្រូវមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការបោះឆ្នោត និងគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ ព្រមទាំងអ្នកសង្កេតការណ៍ (ប្រសិនបើមាន)។ ការមិនព្រមចុះហត្ថលេខារបស់អ្នកសង្កេតការណ៍ មិនអាចធ្វើឱ្យកំណត់ហេតុបូកសរុបលទ្ធផលបឋមនេះ លែងមានសុពលភាពនោះទេ។

ង- ការបូកសរុបលទ្ធផលផ្លូវការនៃការបោះឆ្នោតប្រធានគណៈមេធាវី

៣.៣១. សមាជិកទទួលបន្ទុកបូកសរុបលទ្ធផលបោះឆ្នោតនៃការិយាល័យនីមួយៗ ត្រូវអង្គុយជុំគ្នានៅតុមួយដែលបានរៀបចំរួចជាស្រេច ដើម្បីស្រង់លទ្ធផលបឋមនៃការិយាល័យនីមួយៗចូលទៅក្នុងរបាយការណ៍បូកសរុបលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី (គំរូមានជាឧបសម្ព័ន្ធ) ក្រោមការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់របស់ប្រធានការិយាល័យនីមួយៗ។

៣.៣២. របាយការណ៍បូកសរុបលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី ត្រូវមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការបោះឆ្នោត និងប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ ព្រមទាំងអ្នកសង្កេតការណ៍(ប្រសិនបើមាន)។ ការមិនព្រមចុះហត្ថលេខារបស់អ្នកសង្កេតការណ៍ មិនអាចធ្វើឱ្យរបាយការណ៍នេះលែងមានសុពលភាពនោះទេ។

៣.៣៣. របាយការណ៍បូកសរុបលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី ត្រូវបានបោះពុម្ពចេញពីប្រព័ន្ធកុំព្យូទ័រ។

៣.៣៤. តួលេខសំឡេងឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ ត្រូវស្របគ្នានឹងតួលេខក្នុងរបាយការណ៍កត់ត្រាដោយដៃលើក្រដាសនិងលើក្ដារខៀន។

៣.៣៥. បេក្ខជនដែលទទួលបានសំឡេងគាំទ្រភាគច្រើនដាច់ខាតនៃសមាជិកគណៈមេធាវីទាំងមូល (៥០%បូក១នៃសមាជិកគណៈមេធាវីទាំងមូល) ត្រូវបានជ្រើសតាំងជាប្រធានគណៈមេធាវី។

៣.៣៦. បន្ទាប់ពីរាប់សន្លឹកឆ្នោតរួច សមាជិកទទួលរៀបចំនិងរៀបរយសន្លឹកឆ្នោត ត្រូវទទួលបន្ទុកវេចខ្ចប់សន្លឹកឆ្នោតដោយដាក់សន្លឹកឆ្នោតបានការក្នុងថង់មួយ សន្លឹកឆ្នោតមិនបានការក្នុងថង់មួយ និងសន្លឹកឆ្នោតខូចក្នុងថង់មួយផ្សេងទៀត ហើយកញ្ចប់សន្លឹកឆ្នោតទាំងបីថង់នេះត្រូវប្រេកក្នុងថង់ធំរួមមួយ។

ច- ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីលើកទី២

៣.៣៧. ក្នុងករណីលទ្ធផលនៃការឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី ពុំមានបេក្ខជនណាទទួលបានសំឡេងគាំទ្រលើសពីពាក់កណ្ដាលនៃសមាជិកគណៈមេធាវីទាំងមូល (៥០%បូក១នៃសមាជិកគណៈមេធាវីទាំងមូល) គណៈកម្មការបោះឆ្នោតត្រូវរៀបចំបោះឆ្នោតជាលើកទី២ បន្ទាប់ពីបញ្ចប់ការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាគណៈមេធាវី។

៣.៣៨. អ្នកដែលមានសិទ្ធិបោះឆ្នោតលើកទី២ គឺមេធាវីមានសិទ្ធិបោះឆ្នោតដែលមានវត្តមាននៅក្នុងមហាសន្និបាត។ ចំពោះមេធាវីដែលបានប្រគល់សិទ្ធិឱ្យគេបោះឆ្នោតជំនួសនៅពេលបោះឆ្នោតលើកទី១ ពុំមានសិទ្ធិបោះឆ្នោតឡើយ។

៣.៣៩. ក្រៅពីការអនុវត្តតាមចំណុចទី ៣.៣៧ និងចំណុច ៣.៣៨ ខាងលើ នីតិវិធីក្នុងដំណើរការបោះឆ្នោត និងនីតិវិធីក្នុងដំណើរការផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីលើកទី២ នេះ ត្រូវប្រព្រឹត្តទៅដូចការបោះឆ្នោតលើកទី១ ដែរ។

៣.៤០. បេក្ខជនដែលទទួលបានសំឡេងគាំទ្រភាគច្រើននៃសមាជិកវត្តមាននាពេលបោះឆ្នោត ត្រូវបានជ្រើសតាំងជាប្រធានគណៈមេធាវី។ ក្នុងករណីទទួលបានសំឡេងគាំទ្រស្មើគ្នា បេក្ខជនដែលមានវ័យចាស់ជាងគេ ត្រូវបានជ្រើសតាំង។

## ជំពូកទី ៤
## នីតិវិធីក្នុងដំណើរការផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោត
## សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី

ក- ការផ្ទៀងផ្ទាត់ និងការកំណត់សន្លឹកឆ្នោតបានការឬមិនបានការ

៤.១. ការិយាល័យបោះឆ្នោតនឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត ហើយគណៈកម្មការការិយាល័យបោះឆ្នោតទាំងអស់នឹងក្លាយជាគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត នៅពេលចាប់ផ្តើមរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាគណៈមេធាវី។

៤.២. ប្រធានការិយាល័យបោះឆ្នោត នឹងក្លាយជាប្រធានការិយាល័យរាប់សន្លឹកឆ្នោត ដែលមានតួនាទីកាត់សោឃ្លុំហិបឆ្នោត និងយកសន្លឹកឆ្នោតម្តងមួយៗចេញពីក្នុងហិបឆ្នោត ដើម្បីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ជាមួយនឹងសមាជិកទទួលបន្ទុកផ្ទៀងផ្ទាត់សន្លឹកឆ្នោត (១ រូប) និងជាអ្នកប្រកាសសំឡេងឆ្នោត។

៤.៣. សមាជិកទទួលបន្ទុកពិនិត្យនិងផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកបោះឆ្នោតនឹងក្លាយជាសមាជិកទទួលបន្ទុកផ្ទៀងផ្ទាត់សន្លឹកឆ្នោតដែលបានបោះរួច ជាមួយនឹងឈ្មោះអ្នកដែលបានមកបោះឆ្នោត និងកំណត់ថា ជាសន្លឹកឆ្នោតបានការឬមិនបានការ និងជាអ្នកកត់ត្រាសំឡេងឆ្នោតក្នុងកុំព្យូទ័រ។

៤.៤. សមាជិកទទួលបន្ទុកផ្តល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតនឹងក្លាយជាសមាជិកទទួលកត់ត្រា និងធ្វើកំណត់ហេតុនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនេះ និងជាអ្នកគូសសំឡេងឆ្នោតលើក្រដាស។

៤.៥. សមាជិកទទួលបន្ទុកពិនិត្យមើលការតម្រង់ជួរនិងសណ្តាប់ធ្នាប់ និងសមាជិកទទួលបន្ទុកមើលការដាក់សន្លឹកឆ្នោតក្នុងហិបឆ្នោត នឹងក្លាយជាសមាជិកទទួលរៀបចំនិងរៀបរយសន្លឹកឆ្នោតតាមពំនូកនៃសន្លឹកឆ្នោតបានការនិងសន្លឹកឆ្នោតមិនបានការ និងជាអ្នកគូសសំឡេងឆ្នោតនៅលើក្តារខៀន។

៤.៦. ការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាគណៈមេធាវី ត្រូវចាប់ផ្តើមបន្ទាប់ពីការបញ្ចប់រាប់សន្លឹកឆ្នោតប្រធានគណៈមេធាវី នៅចំពោះមុខអ្នកដែលមានវត្តមានជាក់ស្តែងនៅក្នុងមហាសន្និបាត។

៤.៧. ការផ្ទៀងផ្ទាត់សន្លឹកឆ្នោតដែលបានបោះរួច ជាមួយនឹងឈ្មោះអ្នកដែលបានមកបោះឆ្នោតជាក់ស្តែង រួមទាំងអ្នកប្រគល់សិទ្ធិបោះឆ្នោត ត្រូវធ្វើឡើងតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ។

៤.៨. ក្នុងការផ្ទៀងផ្ទាត់ ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវកាត់សោឃ្លុំហិបឆ្នោតសមាជិកក្រុមប្រឹក្សាគណៈមេធាវី រួចបើកយកសន្លឹកឆ្នោតម្តងមួយៗចេញពីហិបឆ្នោត ដើម្បីរាប់ចំនួនសន្លឹកឆ្នោតដោយផ្ទៀងផ្ទាត់ជាមួយនឹងចំនួនឈ្មោះអ្នកបោះឆ្នោត។

៤.៩. សមាជិកទទួលបន្ទុកផ្ទៀងផ្ទាត់សន្លឹកឆ្នោតត្រូវជួយប្រធានក្នុងការផ្ទៀងផ្ទាត់តួលេខនេះ។

៤.១០. ក្រោយពីពិនិត្យរួច សមាជិកទទួលបន្ទុកកត់ត្រាកំណត់ហេតុនៃការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានបោះរួចជាមួយនឹងឈ្មោះអ្នកបោះឆ្នោតត្រូវធ្វើកំណត់ហេតុនៃការពិនិត្យសន្លឹកឆ្នោត។ កំណត់ហេតុនេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីចំនួនសន្លឹកឆ្នោតជាក់ស្តែងដែលបានប្រើនិងចំនួនអ្នកបោះឆ្នោតជាក់ស្តែង ហើយត្រូវមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការបោះឆ្នោត គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ព្រមទាំងអ្នកសង្កេតការណ៍(ប្រសិនបើមាន)។ ការមិនព្រមចុះហត្ថលេខារបស់អ្នកសង្កេតការណ៍ មិនអាចធ្វើឱ្យកំណត់ហេតុបូកសរុបលទ្ធផលបឋមនេះ លែងមានសុពលភាពនោះទេ។

៤.១១. បន្ទាប់មក ប្រធានការិយាល័យចាប់ផ្តើមលើកយកសន្លឹកឆ្នោតម្តងមួយៗមកពិនិត្យ ថាតើសន្លឹកឆ្នោតបានការឬមិនបានការដូចមានកំណត់ក្នុងចំណុច ៤.១៣ និង ៤.១៤ ខាងក្រោម ដោយមានសមាជិកទទួលបន្ទុកផ្ទៀងផ្ទាត់សន្លឹកឆ្នោតជាជំនួយការក្នុងការពិនិត្យ អមដោយអ្នកសង្កេតការណ៍(ប្រសិនបើមាន)។

៤.១២. ក្នុងករណីសន្លឹកឆ្នោតពិបាកក្នុងការកំណត់ថាជាសន្លឹកឆ្នោតបានការឬមិនបានការ ឬពិបាកកំណត់ពីគំនូសគាំទ្រ ប្រធានការិយាល័យត្រូវទុកសន្លឹកឆ្នោតនោះដោយឡែក ដើម្បីរង់ចាំពិនិត្យឡើងវិញនៅពេលក្រោយ។

៤.១៣. ការកំណត់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ និងការពិនិត្យលើគំនូសគាំទ្រ ត្រូវធ្វើដោយយកចិត្តទុកដាក់បំផុត ដោយត្រូវត្រួតពិនិត្យម្តងមួយៗរហូតដល់អស់សន្លឹកឆ្នោត។

៤.១៤. ក្រោយពីពិនិត្យសន្លឹកឆ្នោតបានការរួចរាល់ហើយ ប្រធានការិយាល័យរាប់សន្លឹកឆ្នោត ត្រូវយកសន្លឹកឆ្នោតដែលមានបញ្ហាមកពិនិត្យឡើងវិញ ដើម្បីកំណត់ថាជាសន្លឹកឆ្នោតបានការឬមិនបានការ រួចធ្វើការសម្រេចជាចុងក្រោយ។

៤.១៥. សមាជិកការិយាល័យបោះឆ្នោត ត្រូវត្រៀមគូសសំឡេងឆ្នោតតាមការហៅរបស់ប្រធាននៅលើក្រដាស នៅលើក្តារខៀន និងកត់ត្រាក្នុងកុំព្យូទ័រ។

៤.១៦. ក្នុងពេលកំពុងផ្ទៀងផ្ទាត់សន្លឹកឆ្នោត សមាជិកដែលត្រូវគូសសំឡេងឆ្នោតនៅលើក្តារខៀន ត្រូវចាត់ចែងរៀបចំឱ្យហើយនូវក្តារខៀនចំនួន ១ ដោយត្រូវសរសេរឱ្យរួចរាល់ផងដែរនូវលេខរៀងរបស់បេក្ខជន តាមលំដាប់ដូចមានក្នុងសន្លឹកឆ្នោត។

៤.១៧. សមាជិកទទួលរៀបចំនិងរៀបរយសន្លឹកឆ្នោត ត្រូវរៀបចំសន្លឹកឆ្នោតឱ្យមានសណ្តាប់ធ្នាប់ជាពំនូកសម្រាប់ត្រៀមឈានដល់ដំណាក់កាលរាប់សន្លឹកឆ្នោត និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត។

ខ- លក្ខណៈសម្គាល់នៃសន្លឹកឆ្នោតបានការឬមិនបានការ

៤.១៨. សន្លឹកឆ្នោតបានការ គឺជាសន្លឹកឆ្នោតរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានត្រាសម្គាល់និងត្រាសម្ងាត់ត្រឹមត្រូវ(ត្រាសើមគណៈមេធាវីនិងត្រាស្ងួតគណៈមេធាវី) និងជាសន្លឹកឆ្នោតដែលមានគំនូសគាំទ្រត្រឹមត្រូវ ព្រមទាំងមានគំនូសគាំទ្របេក្ខជនមិនលើសពីចំនួន ៣៣រូប។

៤.១៩. សន្លឹកឆ្នោតមិនបានការគឺជាសន្លឹកឆ្នោតដែលគ្មានត្រាសម្គាល់និងត្រាសម្ងាត់ត្រឹមត្រូវ (ត្រាសើមគណៈមេធាវីនិងត្រាស្ងួតគណៈមេធាវី) ឬមានគំនូសសញ្ញាគាំទ្រមិនច្បាស់លាស់ មិនមានគំនូសអ្វីទាំងអស់ មានគំនូសក្រៅប្រអប់ មានគំនូសគាំទ្របេក្ខជនលើសពីចំនួន ៣៣រូប សន្លឹកឆ្នោតដាច់ឬរហែក សន្លឹកឆ្នោតមានប្រឡាក់ប្រតាកដែលមិនអាចកំណត់ការគាំទ្របាន ឬសន្លឹកឆ្នោតដែលមានគូសទឹកប៊ិចក្រៅពីពណ៌ខៀវឬខ្មៅ។

គ- ការរាប់សន្លឹកឆ្នោត និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត

៤.២០.ការរាប់សន្លឹកឆ្នោតនឹងត្រូវចាប់ផ្តើមនៅពេលដែលប្រធានការិយាល័យនីមួយៗ ប្រកាសបិទការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនិងប្រកាសចាប់ផ្តើមរាប់សន្លឹកឆ្នោត។

៤.២១.បន្ទាប់មកប្រធានត្រូវយកសន្លឹកឆ្នោតបានការមកប្រកាសការគាំទ្របេក្ខជនណាមួយឱ្យឮៗ ដើម្បីឱ្យអ្នកគូសសំឡេងឆ្នោតលើក្តារខៀន លើក្រដាស និងកត់ត្រាក្នុងកុំព្យូទ័រ គូសតាម។ ការគូសសំឡេងគាំទ្រលើក្រដាសនិងលើក្តារខៀន ត្រូវគូសម្តងមួយ មានរាងជាប្រអប់បួនជ្រុង និងបន្ទាត់បញ្ឆិតចំកណ្តាលស្មើនឹង ៥។

៤.២២.សមាជិកកត់ត្រាសន្លឹកឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ ត្រូវបញ្ចូលទិន្នន័យសំឡេងឆ្នោតតាមការរាប់របស់ប្រធានការិយាល័យបោះឆ្នោតនីមួយៗ ធ្វើយ៉ាងណាឱ្យលទ្ធផលនេះស្របនឹងលទ្ធផលដែលគូសដោយដៃនិងលើក្តារខៀន។

៤.២៣.សន្លឹកឆ្នោតបានការដែលបានរាប់រួច ត្រូវទុកក្នុងពំនូកដោយឡែកមួយទៀត ដែលមានស្លាកសម្គាល់ថា "**សន្លឹកឆ្នោតរាប់ហើយ**"។

៤.២៤. បន្ទាប់ពីរាប់សន្លឹកឆ្នោតរួច ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវចាត់ចែងឱ្យសមាជិកណាម្នាក់ចងសន្លឹកឆ្នោតបានការមួយពំនូក និងសន្លឹកឆ្នោតមិនបានការមួយពំនូក រួចដាក់ប្រេកចូលក្នុងថង់ផ្លាស្ទិកធំរួមមួយ។ បន្ទាប់មកចាត់ចែងឱ្យមានការបូកសរុបលទ្ធផលបឋម។

ឃ- ការបូកសរុបលទ្ធផលបឋមនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី

៤.២៥.សមាជិកទទួលបន្ទុកកត់ត្រានិងធ្វើកំណត់ហេតុនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោត នឹងក្លាយជាសមាជិកទទួលបន្ទុកបូកសរុបលទ្ធផលបោះឆ្នោត។

៤.២៦.បន្ទាប់ពីរាប់សន្លឹកឆ្នោតរួច សមាជិកគូសសម្លេងឆ្នោតលើក្តារខៀនត្រូវបូកសរុបលទ្ធផលបោះឆ្នោតនៅលើក្តារខៀន ហើយសមាជិកទទួលបន្ទុកបូកសរុបលទ្ធផលបោះឆ្នោតត្រូវធ្វើការបូកសរុបលទ្ធផល នៅលើកំណត់ហេតុបូកសរុបលទ្ធផលបឋមសម្រាប់ការិយាល័យនីមួយៗ (គំរូមានជា

ឧបសម្ព័ន្ធ)។

៤.២៧.បន្ទាប់មក ត្រូវធ្វើការផ្ទៀងផ្ទាត់គ្នារវាងការបូកសរុបលទ្ធផលបឋម ដោយសមាជិកគូសសំឡេងឆ្នោតលើក្ដារខៀន និងសមាជិកទទួលបន្ទុកបូកសរុបលទ្ធផលបោះឆ្នោតនៅលើកំណត់ហេតុ។

៤.២៨.ប្រសិនបើតួលេខមិនស៊ីគ្នា ប្រធានការិយាល័យត្រូវស្វែងរកចំណុចមិនប្រក្រតីទាំងនោះ ហើយក្នុងករណីធ្ងន់ធ្ងរមិនអាចរកឃើញចំណុចមិនប្រក្រតី ចាំបាច់ត្រូវធ្វើការរាប់សន្លឹកឆ្នោតឡើងវិញ។

៤.២៩. កំណត់ហេតុបូកសរុបលទ្ធផលបឋម ត្រូវមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការបោះឆ្នោត និងគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ ព្រមទាំងអ្នកសង្កេតការណ៍ (ប្រសិនបើមាន)។ ការមិនព្រមចុះហត្ថលេខារបស់អ្នកសង្កេតការណ៍ មិនអាចធ្វើឱ្យកំណត់ហេតុបូកសរុបលទ្ធផលបឋមនេះ លែងមានសុពលភាពនោះទេ។

ង- ការបូកសរុបលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី

៤.៣០. សមាជិកទទួលបន្ទុកបូកសរុបលទ្ធផលបោះឆ្នោតនៃការិយាល័យនីមួយៗ ត្រូវអង្គុយជុំគ្នានៅតុមួយដែលបានរៀបចំរួចជាស្រេច ដើម្បីស្រង់លទ្ធផលបឋមនៃការិយាល័យនីមួយៗចូលទៅក្នុងរបាយការណ៍បូកសរុបលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី (គំរូមានជាឧបសម្ព័ន្ធ) ក្រោមការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់របស់ប្រធានការិយាល័យនីមួយៗ។

៤.៣១. របាយការណ៍បូកសរុបលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី ត្រូវមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការបោះឆ្នោត និងប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ ព្រមទាំងអ្នកសង្កេតការណ៍(ប្រសិនបើមាន)។ ការមិនព្រមចុះហត្ថលេខារបស់អ្នកសង្កេតការណ៍ មិនអាចធ្វើឱ្យរបាយការណ៍នេះលែងមានសុពលភាពនោះទេ។

៤.៣២. របាយការណ៍បូកសរុបលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី ត្រូវបានបោះពុម្ពចេញពីប្រព័ន្ធកុំព្យូទ័រ។

៤.៣៣. តួលេខសំឡេងឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ ត្រូវស្របគ្នានឹងតួលេខក្នុងរបាយការណ៍កត់ត្រាដោយដៃលើក្រដាសនិងលើក្ដារខៀន។

៤.៣៤. បេក្ខជនដែលទទួលបានសំឡេងគាំទ្រច្រើនជាងគេតាមលំដាប់ចំនួន៣៣រូប ត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាគណៈមេធាវី។ ក្នុងករណីទទួលបានសំឡេងគាំទ្រស្មើគ្នា បេក្ខជនដែលមានវ័យចាស់ជាងគេ ត្រូវបានជ្រើសតាំង។

៤.៣៥. បន្ទាប់ពីរាប់សន្លឹកឆ្នោតរួច សមាជិកទទួលរៀបចំនិងរៀបរយសន្លឹកឆ្នោត ត្រូវទទួលបន្ទុកវេចខ្ចប់សន្លឹកឆ្នោតដោយដាក់សន្លឹកឆ្នោតបានការក្នុងថង់មួយ សន្លឹកឆ្នោតមិនបានការក្នុងថង់មួយ និងសន្លឹកឆ្នោតខូចក្នុងថង់មួយផ្សេងទៀត ហើយកញ្ចប់សន្លឹកឆ្នោតទាំងបីថង់នេះត្រូវច្រកក្នុងថង់ធំរួមមួយ។

## ជំពូកទី ៥
## ការប្រកាសលទ្ធផលនៃការបោះឆ្នោត

ក- ការរាយការណ៍លទ្ធផលនៃការបោះឆ្នោត

៥.១. បន្ទាប់ពីការរាប់សន្លឹកឆ្នោតប្រធានគណៈមេធាវីរួចរាល់ ប្រធានការិយាល័យបោះឆ្នោតទាំងអស់ត្រូវប្រគល់និងរាយការណ៍អំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី ជូនប្រធានគណៈកម្មការបោះឆ្នោត ដើម្បីប្រធានគណៈកម្មការបោះឆ្នោតមានមូលដ្ឋានរាយការណ៍ជូនប្រធានគណៈមេធាវី។

៥.២. បន្ទាប់ពីការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាគណៈមេធាវីរួចរាល់ ប្រធានការិយាល័យបោះឆ្នោតទាំងអស់ ត្រូវប្រគល់និងរាយការណ៍អំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី ជូនប្រធានគណៈកម្មការបោះឆ្នោត ដើម្បីប្រធានគណៈកម្មការបោះឆ្នោតមានមូលដ្ឋានរាយការណ៍ជូនប្រធានគណៈមេធាវី។

ខ- ការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីនិងសមាជិកក្រុមប្រឹក្សាគណៈមេធាវី

៥.៣. ប្រធានគណៈកម្មការបោះឆ្នោតត្រូវឡើងរាយការណ៍អំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីនិងសមាជិកក្រុមប្រឹក្សាគណៈមេធាវី ជូនប្រធានគណៈមេធាវីនៅក្នុងមហាសន្និបាតគណៈមេធាវី។

៥.៤. បេក្ខជនដែលទទួលបានសំឡេងគាំទ្រភាគច្រើនដាច់ខាតនៃសមាជិកគណៈមេធាវីទាំងមូល (៥០%បូក១នៃសមាជិកគណៈមេធាវីទាំងមូល) ត្រូវបានជ្រើសតាំងជាប្រធានគណៈមេធាវី ឬបេក្ខជនដែលទទួលបានសំឡេងគាំទ្រភាគច្រើននៃសមាជិកវត្តមាននាពេលបោះឆ្នោត ត្រូវបានជ្រើសតាំងជាប្រធានគណៈមេធាវី ក្នុងករណីបោះឆ្នោតលើកទី២។

៥.៥. ដោយឡែកចំពោះការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី បេក្ខជនដែលទទួលបានសំឡេងគាំទ្រច្រើនជាងគេតាមលំដាប់ចំនួន៣៣រូប ត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាគណៈមេធាវី។ ក្នុងករណីទទួលបានសំឡេងគាំទ្រស្មើគ្នា បេក្ខជនដែលមានវ័យចាស់ជាងគេ ត្រូវបានជ្រើសតាំង។

៥.៦. ប្រធានគណៈមេធាវីត្រូវប្រកាសលទ្ធផលបោះឆ្នោតផ្លូវការជូនមហាសន្និបាត។

## ជំពូកទី ៦
## ការដោះស្រាយការតវ៉ានៅក្នុងពេលបោះឆ្នោតនិងរាប់សន្លឹកឆ្នោត

៦.១. នៅពេលមានការតវ៉ាលើបញ្ហាអ្វីមួយក្នុងដំណើរការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ប្រធានការិយាល័យបោះឆ្នោត មានភារកិច្ចដោះស្រាយឱ្យអស់លទ្ធភាព។ ក្នុងករណីមិនអាចដោះស្រាយបាន ត្រូវរាយការណ៍ជូនប្រធានគណៈកម្មការបោះឆ្នោត ដើម្បីដោះស្រាយបន្ត។

